# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១២...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសាកលវិទ្យាល័យមានជ័យ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

**មាត្រា ១.-**

បង្កើតសាកលវិទ្យាល័យមួយ ស្ថិតនៅតាមផ្លូវជាតិលេខ៥ ក្នុងឃុំ ទឹកថ្លា ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

ដែលមានឈ្មោះថា សាកលវិទ្យាល័យមានជ័យ " Mean Chey University " ហៅកាត់ជាភាសាខ្មែរ "ស.ម.ជ." និង ហៅកាត់ជាភាសាអង់គ្លេស "M.C.U" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ២..**

សាកលវិទ្យាល័យមានជ័យ មានតួនាទី ជាមជ្ឈមណ្ឌលបណ្តុះបណ្តាល ធនធានមនុស្ស ស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស និង លើកស្ទួយអត្តសញ្ញាណជាតិ ។

**មាត្រា ៣..**

ចំពោះមុខសាកលវិទ្យាល័យមានជ័យ ធ្វើការបណ្តុះបណ្តាលកំរិតបរិញ្ញាប័ត្ររង និងបរិញ្ញាប័ត្រ តាមកម្មវិធីសិក្សា ដែលមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤..**

សាកលវិទ្យាល័យមានជ័យមាន ៥ មហាវិទ្យាល័យ :

១- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា

២- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៣- មហាវិទ្យាល័យសង្គមសាស្ត្រ និងអភិវឌ្ឍន៍សហគមន៍

៤- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍

៥- មហាវិទ្យាល័យកសិកម្ម និងកែច្នៃអាហារ

ទៅអនាគត សាកលវិទ្យាល័យមានជ័យ នឹងអាចបើកមហាវិទ្យាល័យ ឯកទេស កំរិត ឬប្រភេទអប់រំផ្សេង ទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥..**

សាកលវិទ្យាល័យមានជ័យ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការ-អភិវឌ្ឍន៍ និងការងារពាក់ព័ន្ធផ្សេងៗទៀត របស់សាកលវិទ្យាល័យ ។

**មាត្រា ៦..**

សាកលវិទ្យាល័យមានជ័យ ដឹកនាំដោយសាកលវិទ្យាធិការមួយរូប និងសាកលវិទ្យាធិការរងមួយរូប ឬច្រើនរូប ជាជំនួយការ ។

**មាត្រា ៧..**

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រង របស់សាកលវិទ្យាល័យមានជ័យ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង អប់រំ យុវជន និងកីឡា ។

**មាត្រា ៨..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំសាស្ត្រាចារ្យ មន្ត្រីរាជការ ក្របខ័ណ្ឌមុខងារសាធារណៈ ឱ្យបំពេញការនៅក្នុងសាកលវិទ្យាល័យមានជ័យ តាមការសម្រេចយល់ព្រម ពីទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៩..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តបន្ទាយមានជ័យត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ៩
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ